# BACCALAURÉAT GÉNÉRAL

**SESSION 2017**

## CAMBODGIEN

**Lundi 19 juin 2017**

LANGUE VIVANTE **1**

Série **L –** Durée de l'épreuve : **3 heures** – coefficient : **4**

Séries **ES-S** – Durée de l'épreuve : **3 heures** – coefficient : **3**

**Le candidat traitera, dans la langue étrangère, l'ensemble des questions de l'épreuve pour laquelle il compose.**

*L'usage des calculatrices électroniques et du dictionnaire est interdit.*

Dès que ce sujet vous est remis, assurez-vous qu'il est complet.
Ce sujet comporte 4 pages numérotées de 1/4 à 4/4.

**Répartition des points**

| | |
|---|---|
| Compréhension de l'écrit | 10 points |
| Expression écrite | 10 points |

នៅថ្ងៃទី ២៤ ធ្នូនេះ ពលរដ្ឋខ្មែរជាច្រើន ជាពិសេសយុវវ័យតែម្តង បាននាំគ្នាប្រារព្ធពិធីបុណ្យណូអែល បុគ្រីស្មាស់ យ៉ាងព្រោងព្រាត ។ ការសប្បាយរីករាយ គឺជាសេរីភាពដែលមិនអាចឃាត់ឃាំងបានរបស់មនុស្សសម័យថ្មី ប៉ុន្តែ បុណ្យណូអែល ដែលកំពុងរីកដុះដាលនៅលើទឹកដីដែលពលរដ្ឋជាង ៩០ ភាគរយកាន់ព្រះពុទ្ធសាសនា ជាព្រឹត្តិការណ៍គួរឲ្យចាប់អារម្មណ៍ ។

*តាំងពីប៉ុន្មានថ្ងៃមកហើយ ពោលគឺ ចាប់ពីដើមខែធ្នូមក ការរំជើបរំជួលអំពីបុណ្យណូអែល បានចាប់ផ្តើមនៅភ្នំពេញ និងនៅទីប្រជុំជនដទៃទៀត ។ ដើមសាប៉ាំង ដែលរចនាដោយអំពូលភ្លើង និងក្រដាសព័ណ៌ភ្លឺផ្លេក អមដោយកាដូជាច្រើន ត្រូវបានគេដាក់តាំងយ៉ាងព្រោងព្រាត នៅតាមហាងទំនិញធំៗ ឬនៅពីមុខក្រុមហ៊ុនអាជីវកម្ម ឬសណ្ឋាគារមួយចំនួន ។ វាមិនចម្លែកទេ ប្រសិនបើហាងទំនិញ ឬក្រុមហ៊ុនទាំងនោះជារបស់ជនបរទេស ប៉ុន្តែ ជាទូទៅគឺជនជាតិខ្មែរជាម្ចាស់កម្មសិទ្ធិ ។*

*នៅតាមសាលាឯកជនជាច្រើន គេបានរៃអង្គាសលុយពីសិស្ស ដើម្បីរៀបចំបុណ្យណូអែលដែរ ។ ឪពុកម្តាយឬអាណាព្យាបាលមួយចំនួន ក៏បានទិញមួកព័ណ៌ក្រហម ដែលគេហៅថាមួកណូអែលឬគ្រីស្មាស់ មកបំពាក់ឲ្យកូន ។ វប្បធម៌បុណ្យណូអែល កាន់តែពេញនិយមខ្លាំងឡើងៗ នារយៈពេលចុងក្រោយនេះ ។ បុណ្យណូអែលបានក្លាយជាពិធីបុណ្យកម្សាន្តសប្បាយរបស់យុវវ័យខ្មែរជាច្រើន ។*

*ជាការពិតណាស់ ប្រជាពលរដ្ឋកម្ពុជាកាន់ព្រះពុទ្ធសាសនាជាង ៩០ ភាគរយ ។ បើយោងតាមតួលេខនេះ គេប្រហែលជាពិបាកនឹងគិតស្រមៃណាស់ថា បុណ្យសាសនាគ្រិស្តមួយនេះ អាចមានប្រជាប្រិយភាពដល់ម៉្លឹង ។ តើហេតុអ្វីបានជាដូច្នេះ? ពិតហើយ ក្នុងសម័យសកលភាវូបនីយកម្មនេះ មានរឿងរ៉ាវច្រើនណាស់ ដែលធ្វើឲ្យសង្គមផ្លាស់ប្តូរ និងទទួលឥទ្ធិពលពីគ្នាទៅវិញទៅមកយ៉ាងឆាប់រហ័ស ។ ជាកត្តាសត្យានុម័តសង្គមមួយ ដែលទន់ខ្សោយ តែងតែទទួលយកវប្បធម៌ពីប្រទេសផ្សេងដែលរុងរឿងជាងខ្លួន ។ ដូច្នេះ កម្ពុជាដែលជាប្រទេសក្រីក្រ ពិតជាមិនអាចគេចផុតពីការទទួលយកវប្បធម៌បុណ្យណូអែល ។*

*ម្យ៉ាងទៀត កម្ពុជាបានបើកទូលាយចំពោះជំនឿសាសនា ដែលជាកត្តាមួយទៀត ធ្វើឲ្យពលរដ្ឋមានសិទ្ធិពេញលេញ ក្នុងការជ្រើសរើសសាសនាណាមួយដែលខ្លួនពេញចិត្ត ។ នៅមានហេតុផលមួយទៀត ដែលជំរុញឲ្យពិធីបុណ្យណូអែល កាន់តែមានប្រជាប្រិយភាពនៅកម្ពុជា នោះគឺហេតុផលជំនួញ ។ អ្នកធ្វើជំនួញបានឆ្លៀតយកឱកាសនេះ ដើម្បីឃោសនាលក់ទំនិញរបស់ខ្លួន ។*

*ហេតុផលចុងក្រោយ ដែលគេមិនអាចមើលរំលងបាននោះ គឺ វប្បធម៌មិនសូវរឹងមាំក្នុងចំណោមពលរដ្ឋខ្មែរ ពោលគឺ ជនជាតិខ្មែរតែងឆាប់ទទួលយកវប្បធម៌បរទេស ទោះជាដោយចេតនា ឬអចេតនាក្តី ។ នេះបណ្តាលមកពីការបាត់បង់មោទនភាពជាតិរបស់ពួកគេ បន្ទាប់ពីបានឆ្លងកាត់សង្គ្រាមស៊ីវិល និងជម្លោះនយោបាយមិនចេះចប់ ដែលធ្វើឲ្យសង្គមមិនសូវស្គាល់ភាពរុងរឿងនឹងគេ ។ ការទទួលយកបុណ្យណូអែលដោយមិនដឹងខ្លួន គឺជាឧទាហរណ៍ជាក់ស្តែង ។*

*អ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺអ្នកប្រារព្ធពិធីនេះ ភាគច្រើន គឺជាអ្នកកាន់ព្រះពុទ្ធសាសនា តែពួកគេមិនបានគិតថា ណូអែលជាពិធីសម្រាប់គ្រិស្តបរិស័ទទេ ហើយក៏មិនបានគិតថា ការប្រារព្ធពិធីនេះនឹងធ្វើឲ្យប៉ះពាល់ដល់ព្រះពុទ្ធសាសនាអ្វីនោះដែរ ។ និយាយតាមបែបផ្សេង គឺជាទង្វើបែបមោហោគតិ (មិនយល់) តែប៉ុណ្ណោះ ពោលគឺការមិនដឹងថា ខ្លួនមានឫសគល់ចេញពីណា ហើយត្រូវធ្វើដំណើរទៅណា? នេះជាបញ្ហាសំខាន់ ។*

*អ្វីដែលគួរឲ្យសង្វេគ គឺ មនុស្សចាស់ (ឪពុកម្តាយ អាណាព្យាបាល ឬរហូតដល់គ្រូបង្រៀន) បាននាំក្មេងឲ្យទទួលយកវប្បធម៌ដទៃដោយមិនដឹងខ្លួន ។ ដោយសារតែសង្គមទាំងមូលខ្វះមូលដ្ឋានគ្រឹះរឹងមាំនេះហើយ បានជាគេបណ្តោយ ឬក៏ជួយជំរុញឲ្យកូនចៅជំនាន់ក្រោយដើរខុសផ្លូវកាន់តែឆ្ងាយ ។ អ្នកខ្លះជាពុទ្ធសាសនិកជនសុទ្ធសាធ តែបែរជាពាក់ខ្សែកបន្តោងសញ្ញាជើងក្អែក ដែលជានិម្មិតរូបសញ្ញារបស់គ្រិស្តសាសនាទៅវិញ ។ ពួកគេមិនបានគិតដល់បញ្ហាសាសនាអ្វីឡើយ តែគិតត្រឹមតែជាការលម្អរាងកាយតែប៉ុណ្ណោះ ។ ការត្រេក*

ត្រអាលនឹងបុណ្យគ្រីស្ទាស់ ក៏មានន័យដូចគ្នានេះដែរ ។

តាមពិត ផលវិបាកធំបំផុត ចំពោះបញ្ហានេះ គឺ ការបង្ហាញពីភាពកម្សោយនៃវប្បធម៌របស់ខ្មែរនេះតែម្តង ។ បើទោះបីជាទង្វើនេះគ្មានផលប៉ះពាល់ធំដុំដល់ព្រះពុទ្ធសាសនា ដោយសារថា អ្នកប្រារព្ធបុណ្យណូអែល មិនបានផ្លាស់ប្តូរសាសនាទេ និងម្យ៉ាងទៀត វាគ្រាន់តែជាការបង្កើតកម្មវិធីសប្បាយរបស់មនុស្សសម័យថ្មីតែប៉ុណ្ណោះ ប៉ុន្តែ ប្រសិនបើខ្មែរស្គាល់ច្បាស់ឫសគល់របស់ខ្លួន គេអាចនឹងសប្បាយតាមបែបផ្សេង គឺត្រឹមការចែករំលែកការសប្បាយជាមួយមិត្តភ័ក្តិបរទេសជាការស្រេច តែក្នុងនាមជាពុទ្ធសាសនិកជន គេមិនគួរត្រេកត្រអាលនឹងបញ្ហានេះឡើយ ពីព្រោះចូរកុំភ្លេចថា « ព្រះពុទ្ធសាសនាគឺជាសាសនារបស់រដ្ឋ » ៕

« វប្បធម៌គ្រិស្តចាក់ឫសលើផែនដីព្រះពុទ្ធ ? »

ថ្មី ៗ ២៥ ធ្នូ ២០១៦ (https://thmeythmey.com/?page=detail&ctype=article&id=47880&lg=kh) ។

**Vocabulaire ~ វាក្យសព្ទ**

◎ កត្តា ៖ facteur(s)
◎ កត្តាសត្យានុម័ត ៖ facteur(s) concret(s), facteur(s) objectif(s)
◎ កម្មវិធី ៖ programme
◎ កម្សោយ (ឬ ភាពកម្សោយ) ៖ faiblesse
◎ ក្នុងនាមជា ៖ en tant que
◎ ក្រុមហ៊ុនអាជីវកម្ម ៖ compagnie professionnelle, compagnie comerciale
◎ គ្រិស្តបរិស័ទ ៖ chrétien, fidèle chrétien
◎ គ្រិស្តសាសនា (គ្រិស្ត អានថា /គ្រឹស/) ៖ christianisme
◎ គ្រឹះ ៖ fondement, fondations
◎ ឃោសនា ៖ faire de la propagande, faire de la réclame
◎ ដោយចេតនា ៖ volontairement
◎ ដោយអចេតនា ៖ involontairement
◎ ទង្វើ ៖ acte
◎ ទិវា ៖ journée
◎ ទិវានៃក្តីស្រឡាញ់ ៖ fête des amoureux (littéral. “fête de l’amour”), Saint-Valentin
◎ នាម ៖ nom
◎ និមិត្តរូប ៖ symbole
◎ ប្រជាប្រិយភាព ៖ popularité
◎ ប្រជាពលរដ្ឋ ៖ citoyen
◎ ប្រារព្ធ ៖ ធ្វើ, តាំងផ្តើម, ផ្តួចផ្តើម, ប្រុងប្រៀប
◎ ផលវិបាក ៖ conséquence(s)
◎ ពលរដ្ឋ ៖ citoyen
◎ ពុទ្ធសាសនា ៖ bouddhisme
◎ ពុទ្ធសាសនិកជន ៖ bouddhiste
◎ ព្រឹត្តិការណ៍ ៖ événement
◎ ព្រះពុទ្ធសាសនា ៖ bouddhisme
◎ មូលដ្ឋាន ៖ base(s)
◎ មោទនភាព ៖ fierté
◎ មោហោគតិ ៖ ignorance
◎ ម្ចាស់កម្មសិទ្ធិ ៖ propriétaire
◎ យុវវ័យ ៖ jeunesse
◎ រចនា ៖ តាក់តែង, ធ្វើឲ្យវិចិត្រផ្សេង ៗ, រៀបរៀងឲ្យត្រូវរបៀបបែបយ៉ាង
◎ វប្បធម៌ ៖ culture
◎ សកលភាវូបនីយកម្ម ៖ mondialisation
◎ សង្គម ៖ société ; social
◎ សង្វេគ ៖ préoccupation ; être préoccupé
◎ សណ្ឋាគារ ៖ hôtel
◎ សតវត្ស ៖ siècle
◎ សត្យានុម័ត ៖ concret, objectif
◎ សាសនាគ្រិស្ត ៖ christianisme
◎ សាលាឯកជន ៖ école privée
◎ សិទ្ធិ ៖ droit(s)
◎ អាណាព្យាបាល ៖ tuteur
◎ ឥទ្ធិពល ៖ influence
◎ ឧទាហរណ៍ ៖ exemple
◎ ឯកជន ៖ privé

## TRAVAIL À FAIRE PAR LE CANDIDAT

### I. COMPRÉHENSION DE L'ÉCRIT : (10 points)

**១-ក** តើបុណ្យណូអែល ក៏មានឈ្មោះម្យ៉ាងទៀតថាដូចម្ដេច ? (១ ពិន្ទុ)

**១-ខ** ហេតុអ្វីបានជាវាជាការគួរឲ្យចម្លែក ដែលមានដើមសាប៉ាំងតាមហាងធំ ៗ និងនៅពីមុខក្រុមហ៊ុនអាជីវកម្ម ឬ សណ្ឋាគារមួយចំនួន ? (២ ពិន្ទុ)

**១-គ** បើតាមអ្នកនិពន្ធ មូលហេតុអ្វីខ្លះបានជាបុណ្យណូអែល មានការពេញនិយមនៅស្រុកខ្មែរ ? (៤ ពិន្ទុ)

**១-ឃ** តើមានប្រជាពលរដ្ឋខ្មែរប៉ុន្មានភាគរយ ដែលកាន់ពុទ្ធសាសនា ? (១ ពិន្ទុ)

**១-ង** តើហេតុអ្វីបានជាមានខ្មែរ ដែលជាពុទ្ធសាសនិកជន ពាក់បន្ដោងសញ្ញាជើងក្អែក ? (២ ពិន្ទុ)

### II. EXPRESSION ÉCRITE : (10 points)

**Afin de respecter l'anonymat de votre copie, vous ne devez pas signer votre composition, citer votre nom, celui d'un camarade ou celui de votre établissement.**

**Traitez un des deux sujets. (250 mots minimum)**

**២-ក** នៅស្រុកខ្មែរ រហូតដល់ដើមសតវត្សទី ២១ គេមិនធ្លាប់ប្រារព្ធបុណ្យណូអែលទេ ។ គេធ្លាប់ប្រារព្ធបុណ្យចូលឆ្នាំខ្មែរ បុណ្យចូលឆ្នាំចិន (ព្រោះខ្មែរមួយចំនួន មានខ្សែស្រឡាយចិន) បុណ្យកាន់បិណ្ឌ ។ល។ តែសព្វថ្ងៃនេះ ខ្មែរ ជាពិសេសយុវជន ចូលចិត្តប្រារព្ធបុណ្យចូលឆ្នាំសកល បុណ្យណូអែល ទិវានៃក្ដីស្រឡាញ់ (សាំងវ៉ាឡង់តាំង) ផងដែរ ។ ឯនៅស្រុកបារាំង បើតាមប្រពៃណី គេប្រារព្ធបុណ្យទូស្សាំងតែសព្វថ្ងៃ គេក៏និយមធ្វើបុណ្យហាល់ឡូវីនយ៉ាងសប្បាយរីករាយ ជាបុណ្យរបស់អៀរឡង់ ដែលគេបានខ្ចីយកតាមរយៈវប្បធម៌អាមេរិក ។ តើការខ្ចីយកបុណ្យបរទេសបែបនេះហើយ ដែលគេប្រារព្ធយ៉ាងអ៊ឹកធឹកនិងសប្បាយរីករាយ ជាការបង្ហាញពីចិត្តគំនិតទូលាយ និងមិនលម្អៀង របស់សង្គមខ្មែរនិងបារាំង ឬក៏បង្ហាញពីសង្គមដែលមានមូលដ្ឋានមិនរឹងមាំ ? តើអ្នកមានយោបល់យ៉ាងដូចម្ដេច ? ចូររៀបរាប់ឲ្យបានក្បោះក្បាយ ។

**២-ខ** អ្នករស់នៅស្រុកបារាំង ។ តើអ្នកចូលចិត្តបុណ្យណាមួយ ឬ បុណ្យណាខ្លះ ក្នុងចំណោមបុណ្យបារាំង និងបុណ្យខ្មែរទាំងឡាយ ? ចូររៀបរាប់ឲ្យបានក្បោះក្បាយ ៕